# ខោនធី LOS ANGELES
# មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

# តើមានអ្វីថ្មីនៅក្នុងការបោះឆ្នោតបឋមឆ្នាំ 2022?

## ផលប៉ះពាល់នៃការជំរឿននិងគណៈកម្មការពលរដ្ឋរៀបចំព្រំដែនមណ្ឌលឡើងវិញ

- បន្ទាប់ពីជំរឿនជាតិ (បានធ្វើឡើងក្នុងឆ្នាំ 2020) គណៈកម្មាធិការរៀបចំព្រំដែនមណ្ឌលឡើងវិញរបស់ពលរដ្ឋ រដ្ឋកាលីហ្វ័រញ៉ា បានធ្វើបច្ចុប្បន្នភាពព្រំដែនមណ្ឌលឡើងវិញទូទាំងរដ្ឋ
- អ្នកបោះឆ្នោតខ្លះអាចស្ថិតនៅក្នុងមណ្ឌលថ្មីនៃសភា សភារដ្ឋ ព្រឹទ្ធសភារដ្ឋ និងគណៈកម្មការសមភាពរដ្ឋ
- អ្នកបោះឆ្នោតនឹងឃើញការប្រកួតប្រជែង និងបេក្ខជនសម្រាប់មណ្ឌលថ្មីរបស់ពួកគេ។
- ពិនិត្យមើលមណ្ឌលណាដែលអ្នកកំពុងរស់នៅដោយចូលទៅកាន់ **LAVOTE.GOV/MYDISTRICT**




## ការបោះឆ្នោតពីរដំណាលគ្នាសំរាប់អាសនៈព្រឹទ្ធសភាអាមេរិក

- មានការប្រកួតព្រឹទ្ធសភាអាមេរិកចំនួនពីរនៅលើសន្លឹកឆ្នោត។
  - ការប្រកួតមួយសម្រាប់អាណត្តិរយៈពេល 6 ឆ្នាំជាធម្មតា ដែលនឹងបញ្ចប់នៅថ្ងៃទី 3 ខែមករា ឆ្នាំ 2029
  - ការប្រកួតមួយទៀតសម្រាប់រយៈពេលសេសសល់នៃអាណត្តិនាពេលបច្ចុប្បន្ន ដែលនឹងបញ្ចប់នៅថ្ងៃទី 3 ខែមករា ឆ្នាំ 2023

▽ kនបោះឆ្នោតអាចបោះឆ្នោតឲ្យការប្រកួតទាំងពីរបាន។



# ខោនធី LOS ANGELES
# មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

## តើមានអ្វីថ្មីនៅក្នុងការបោះឆ្នោតបឋមឆ្នាំ 2022?

### ការបោះឆ្នោតបឋមពិសេសសំរាប់សភារដ្ឋ មណ្ឌលទី 62

- ការបោះឆ្នោតពិសេសមួយបានធ្វើឡើងនៅថ្ងៃទី 5 ខែមេសា ឆ្នាំ 2022 ដើម្បីបំពេញអាសនៈទំនេរនៅមណ្ឌលសភាទី 62
- បេក្ខជនកំពូលពីររូបដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេនៅការបោះឆ្នោតពិសេស នឹងត្រូវបានចូលទៅការបោះឆ្នោតសារជាថ្មីសំរាប់អាណត្តិដែលនៅសេសសល់នៃអាណត្តិខ្លី (ចប់នៅថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2022)
- ការបោះឆ្នោតសារជាថ្មីគឺត្រូវបានរួមបញ្ចូលជាមួយនឹងសន្លឹកឆ្នោតការបោះឆ្នោតបឋម ថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2022
- យោងទៅតាមការរៀបចំព្រំដែនមណ្ឌលជាថ្មីអ្នកបោះឆ្នោតជាច្រើនដែលមានសិទ្ធដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតសារជាថ្មីឥឡូវនេះកំពុងរស់នៅក្នុងមណ្ឌលសភាទី 61
- អ្នកបោះឆ្នោតទាំងនោះនឹងឃើញមានការប្រកួតប្រជែងចំនួនពីរនៅលើសន្លឹកឆ្នោតរបស់ពួកគេ៖
  - សមាជិកសភារដ្ឋ មណ្ឌលទី 61 - អាណត្តិពេញ
  - សមាជិកសភារដ្ឋ មណ្ឌលទី 62 - អាណត្តិខ្លី ដែលនឹងបញ្ចប់នៅថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2022
- អ្នកអាចបោះឆ្នោតឲ្យការប្រកួតទាំងពីរបាន

